ក្រុមសៀវភៅការរុករកឃើញ®

# តើព្រះយេស៊ូវ
## ជានរណា?



បោះពុម្ពផ្សាយ ដោយនំម៉ាណាប្រចាំថ្ងៃ

# តើព្រះយេស៊ូវជានរណា?

មនុស្សមានការយល់ឃើញ ខុសៗគ្នាអំពីព្រះយេស៊ូវ តែទន្ទឹមនឹងនោះ មានមនុស្សជាច្រើនបានជឿថា អង្គបុគ្គលឈ្មោះយេស៊ូវ ដែលជាជនជាតិយូដា ដែលបានមានព្រះជន្មគង់នៅ កាលពីជាង២០០០ឆ្នាំមុន គឺជាព្រះដ៏ពិត។ តើធ្វើដូចម្តេចឲ្យយើងអាចជឿថា ទ្រង់ពិតជាព្រះមែន? តែក៏មានមនុស្សជាច្រើនជឿថា ទ្រង់គ្រាន់តែជាមនុស្សល្អម្នាក់ ដែលបានរស់នៅ តាំងពីយូរមកហើយ ដូចនេះ តើទ្រង់ពិតជាព្រះអាទិករ ដែលបានបង្កើតពិភពលោកមកមែនឬ? ការជឿថា ព្រះយេស៊ូវជាព្រះដ៏ពិត គឺជាចំណុចស្នូលដ៏សំខាន់បំផុត នៃជំនឿរបស់គ្រីស្ទបរិស័ទ។ តែមនុស្សជាច្រើនបែរជាអស់សំណើច ពេលដែលយើងអះអាងថា ព្រះយេស៊ូវជាព្រះ។ ដូចនេះ ក្រៅពីអ្វីដែលយើងបានដឹង និងបានឮពីគ្រូគង្វាល ឬគ្រីស្ទបរិស័ទដទៃទៀតដែលយើងស្គាល់ តើយើងដឹងទេថា ព្រះយេស៊ូវមានអត្តសញ្ញាណពិតប្រាកដ ជានរណា?

# ហេតុអ្វីបានជាយើងចាំបាច់ត្រូវដឹងថា ព្រះយេស៊ូវជានរណា?

គ្រីស្ទបរិស័ទបានអះអាងថា ព្រះយេស៊ូវជាព្រះ ហើយទន្ទឹងនឹងនោះ ពួកគេក៏បានហៅទ្រង់ថា ព្រះសង្គ្រោះ ដោយលើកឡើងថា គោលបំណងដែលទ្រង់បានយាងចុះមកផែនដី គឺដើម្បីសង្គ្រោះយើងឲ្យរួចពីបាប។ ព្រះនាម "ព្រះគ្រីស្ទ" គឺមានន័យថា "អ្នកដែលត្រូវបានជ្រើសរើស"។ រីឯព្រះនាម "យេស៊ូវ" វិញ គឺមានន័យថា "ព្រះដែលជួយសង្គ្រោះ"។ ដូចនេះ ព្រះយេស៊ូវ គ្រីស្ទ ជាអង្គដែលត្រូវបានជ្រើសរើស ឲ្យមកជួយសង្គ្រោះយើង(និយាយឲ្យខ្លី ទ្រង់ជា ព្រះសង្គ្រោះរបស់យើង)។ គ្រីស្ទបរិស័ទជឿថា យើងបានទទួលសេចក្តីសង្គ្រោះ ដោយសារព្រះជន្មគង់នៅ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់។ ប៉ុន្តែ តើទ្រង់បានសង្គ្រោះយើង ឲ្យរួចពីអ្វី?

-------------

*"គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង"។*

-រ៉ូម ៣:១០

-------------

ព្រះទ្រង់បានបង្កើតយើងមក ឲ្យរស់នៅជាមួយទ្រង់។ តែយើងបានជ្រើសរើសរស់នៅ ដោយគ្មានទ្រង់ ធ្វើអ្វីតាមចិត្ត រស់នៅដោយខ្លួនឯង ដាក់អាទិភាពឲ្យខ្លួនឯង ហើយឲ្យតម្លៃខ្លួនឯងខ្ពស់ជាងទ្រង់។ ហើយយើងម្នាក់ៗ សុទ្ធតែមានបាប គឺដូចមានសេចក្តីចែងថា "គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង"(រ៉ូម ៣:១០។ យើងគ្រប់គ្នាសុទ្ធតែបានធ្វើព្រងើយដាក់ព្រះ ដែលបានបង្កើតយើងមក។ ព្រះគម្ពីរបានហៅអាកប្បកិរិយ៉ានេះថា "អំពើបាប"។ ហើយឈ្នួលនៃអំពើបាប គឺជាសេចក្តីស្លាប់។ គ្រីស្ទបរិស័ទជឿថា ព្រះគ្រីស្ទ ជាព្រះដែលបានយាងចុះមកផែនដី ដើម្បីបង់ថ្លៃលោះយើងឲ្យរួចពីអំពើបាប ដោយសុគតជំនួសយើងរាល់គ្នា។

ហេតុនេះហើយ វាជាការសំខាន់ណាស់ ដែលយើងត្រូវដឹងច្បាស់ថា ព្រះយេស៊ូវជានរណា។ បើទ្រង់គ្រាន់តែជាមនុស្សសាមញ្ញម្នាក់ ដូចយើងរាល់គ្នា នោះទ្រង់មិនអាចជួយសង្គ្រោះយើងបានទេ។ តែព្រះទ្រង់ល្អឥតខ្ចោះ ហើយក៏គ្មានបាបដែលត្រូវទទួលទោសនោះទេ ដូចនេះ មានតែទ្រង់ទេ ដែលអាចជួយសង្គ្រោះ

យើងបាន ដោយទ្រង់ទទួលយកនូវបាបរបស់យើង ដាក់នៅលើព្រះអង្គទ្រង់ ហើយសុគតជួយយើង។ ហេតុនេះហើយ បានជាយើងចាំបាច់ត្រូវដឹងថា ព្រះយេស៊ូវជាព្រះ ឬមិនមែន ហើយតើទ្រង់ពិតជាអាចជួយសង្គ្រោះយើង ដូចការអះអាងរបស់ទ្រង់ឬទេ?

ដូចមានសេចក្តីចែងទុកមកថា "គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង"។-រ៉ូម ៣:១០

------------

*"ព្រះនាមព្រះយេស៊ូវ គឺមានន័យថា "ព្រះសង្គ្រោះ"។*

------------

ប៉ុន្តែ ធ្វើដូចម្តេចឲ្យយើងអាចជឿអង្គបុគ្គល ដែលបានអះអាងថា ខ្លួនជាព្រះ? យើងគួរតែជៀសវាងមនុស្សដែលតាំងខ្លួនជាព្រះ តែតាមពិតមិនមែនជាព្រះ។ ជាការពិតណាស់ គេមិនគួរហៅអ្នកនោះថា ជាមនុស្សល្អ ឬឆ្លាតឡើយ និយាយឲ្យខ្លី គាត់ប្រាកដជាឡប់ហើយ!

ដូចនេះ ពេលព្រះយេស៊ូវបានអះអាងច្បាស់ៗថា ទ្រង់ជាព្រះ តើទ្រង់ជាមនុស្សឆ្កួត ឬកំពុងនិយាយការពិត។ ដើម្បីឲ្យយើងដឹងច្បាស់ យើងចាំបាច់ត្រូវពិនិត្យមើល គឺមិនគ្រាន់តែស្មាន ឬគិតនោះឡើយ។ និយាយរួម គឺយើងត្រូវការភស្តុតាង។

អ្នកខ្លះគិតថា គេត្រូវមានភស្តុតាង បន្ថែមពីលើការអះអាងរបស់ព្រះគម្ពីរប៊ីបអំពីព្រះយេស៊ូវ។ ពួកគេគិតថា បើទ្រង់ពិតជាបានធ្វើការអស្ចារ្យ និងបាននាំមនុស្សជាច្រើនសណ្ឋិក ឲ្យដើមតាមទ្រង់មែននោះ គេប្រាកដជាបានកត់ត្រាអំពីទ្រង់ នៅក្នុងឯកសារប្រវត្តិសាស្ត្រហើយ។ ការគិតដូចនេះ គឺត្រឹមត្រូវហើយ។

# ភស្តុតាង

ក្នុងចំណោមមនុស្សជាច្រើនដែលបានកត់ត្រាឯកសារប្រវត្តិសាស្ត្រ អំពីព្រះយេស៊ូវ មានបុគ្គលល្បីៗ ដូចជា ប្រវត្តិវិទូ និងមេទ័ពជនជាតិយូដា ឈ្មោះយ៉ូសែបភើស(Josephus ឆ្នាំ ៣៧ មុនគ.ស ដល់ ឆ្នាំ១១៣ គ.ស), សមាជិកសភាជាតិរបស់ចក្រភពរ៉ូម ឈ្មោះ ភ្លីនី ដឺយាំងហ្គើរ(Pliny the Younger ឆ្នាំ ៦១ មុន គ.ស ដល់ ឆ្នាំ ១១៣ គ.ស) និងប្រវត្តិវិទូជនជាតិរ៉ូម៉ាំង ឈ្មោះតាស៊ីតុស(Tacitus ឆ្នាំ៥៦ មុនគ.ស ដល់ឆ្នាំ ១១៧ គ.ស)។

លោកយ៉ូសែបភើស បានហៅព្រះគ្រីស្ទថា "អ្នកប្រាជ្ញ" និង "អ្នកធ្វើការដ៏គួរឲ្យភ្ញាក់ផ្អើល"។ ក្នុងសំបុត្រ ដែលលោកភ្លីនីសរសេរថ្វាយដល់អធិរាជចក្រភពរ៉ូម៉ាំង គាត់បាននិយាយថា ពួកគ្រីស្ទានបានថ្វាយបង្គំ "ព្រះគ្រីស្ទ ដោយទទួលទ្រង់ជាព្រះ"។ លោកតាស៊ីតុសបានកត់សំគាល់ថា "ព្រះគ្រីស្ទ" ជាអ្នកបង្កើតសាសនាមួយ ដែលបះបោរប្រឆាំង ("បះបោរ" គឺដោយសារ សាសនានោះ មិនមែនជាសាសនារបស់ចក្រភពរ៉ូម៉ាំង) ហើយក៏បានបញ្ជាក់ថា ទ្រង់ត្រូវគេកាត់ទោសប្រហារជីវិត តាមការសម្រេចរបស់លោកប៉ុនទាស ពីឡាត់។

អ្នកនិពន្ធទាំងអស់នេះមិនមែនជាអ្នកដើរតាមព្រះគ្រីស្ទទេ តែពួកគេសុទ្ធតែបានទទួលស្គាល់ថា ព្រះយេស៊ូវពិតជាបានមានព្រះជន្មគង់នៅ ក្នុងសម័យនោះមែន ហើយអ្នកដើរតាមទ្រង់ បានគិតថា ទ្រង់ជាព្រះ។ ទោះជាយ៉ាងណាក៏ដោយ ភស្តុតាងភាគច្រើនដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ព្រះយេស៊ូវ គឺមាននៅក្នុងព្រះគម្ពីរបរិសុទ្ធ។ ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា ព្រះយេស៊ូវជាព្រះ។ ព្រះគម្ពីរបានទទួលការត្រួតពិនិត្យ ដោយពួកអ្នកប្រាជ្ញ ជិត២ពាន់ឆ្នាំមកហើយ ហើយពួកគេនៅតែបន្តរកឃើញថា ព្រះគម្ពីរមានអំណះអំណាងដែលអាចទុកចិត្តបាន ហើយត្រឹមត្រូវ។ ឯកសារពីអារ្យធម៌បុរាណ ក៏បានបញ្ជាក់ថា រឿង កាលប្រវត្តិ និងតួអង្គ ក្នុងព្រះគម្ពីរ

*ឯកសារពីអារ្យធម៌បុរាណ ក៏បាន* ***បញ្ជាក់ថា*** *រឿង កាលប្រវត្តិ និងតួអង្គ ក្នុងព្រះគម្ពីរ* ***សុទ្ធតែពិត។***

សុទ្ធតែពិត(សូមស្វែងយល់បន្ថែម ក្នុងសៀវភៅ *តើយើងពិតជាអាចទុកចិត្តព្រះគម្ពីរឬទេ?* ក្នុងគេហទំព័រ ourdailybread.org/lookingdeeper)។

នេះជារឿងសំខាន់។ បើព្រះគម្ពីរមានការអះអាងដ៏ត្រឹមត្រូវ ស្របតាមឯកសារប្រវត្តិសាស្រ្តដទៃទៀតមែន នោះយើងចាំបាច់ត្រូវស្តាប់ការគ្រប់យ៉ាង ដែលព្រះគម្ពីរបាននិយាយអំពីព្រះយេស៊ូវ។ បើយើងដឹងថា ការអះអាងរបស់ព្រះគម្ពីរ អំពីអត្តសញ្ញាណរបស់ព្រះយេស៊ូវ គឺជាការពិត នោះយើងចាំបាច់ត្រូវអានព្រះគម្ពីរ ដើម្បីស្វែងយល់បន្ថែមអំពីការពិតនោះ។ យើងចាំបាច់ត្រូវស្វែងយល់ អំពីការពិត ឲ្យដឹងថា ទ្រង់ជានរណា មានចារិកលក្ខណៈ បុគ្គលិកលក្ខណៈ និងសកម្មភាពអ្វីខ្លះ។ ដូចនេះ ព្រះយេស៊ូវពិតជាមានមែន ប៉ុន្តែ តើទ្រង់ពិតជាព្រះមែនឬ?

*ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា* ***ព្រះយេស៊ូវ*** *ជាព្រះ។*

# ព្រះគម្ពីរ

## ព្រះគម្ពីរសញ្ញាចាស់

ព្រះគម្ពីរសញ្ញាចាស់ ជាផ្នែកមួយនៃព្រះគម្ពីរបរិសុទ្ធ ដែលត្រូវបាននិពន្ធអស់រយៈពេលជាច្រើនរយឆ្នាំ មុនពេលព្រះយេស៊ូវប្រសូត្រ។ មានបទគម្ពីរជាច្រើនបានចែងជាលម្អិត អំពីព្រះសង្គ្រោះ ដែលនឹងយាងមក("ព្រះគ្រីស្ទ") ដែលជាបទទំនាយ ដូចដែលមានចែងក្នុងកណ្ឌជាច្រើន ក្នុងព្រះគម្ពីរសញ្ញាចាស់។ ព្រះជន្មគង់នៅ និងការសុគតរបស់ព្រះយេស៊ូវបានសម្រេចបទទំនាយទាំងនេះ យ៉ាងត្រឹមត្រូវ តាមលក្ខណៈដ៏គួរឲ្យភ្ញាក់ផ្អើល។ សូមយើងមើលបទគម្ពីរមួយចំនួនតូច ក្នុងចំណោមបទគម្ពីរទាំងនោះ ដែលមានដូចជា :

អេសាយ ៧:១៤ *ដូច្នេះព្រះអម្ចាស់ទ្រង់នឹងប្រទានទីសំគាល់១មកអ្នករាល់គ្នា ដោយព្រះអង្គទ្រង់ មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយនឹងឲ្យព្រះនាមថា អេម៉ាញូអែល។*

ព្រះនាម *អេម៉ាញូអែល* គឺមានន័យថា "ព្រះគង់នៅជាមួយយើង" ហើយជាការថ្លែងទំនាយថា ព្រះគ្រីស្ទដែលនឹងយាងមក គឺជាព្រះ។ អ្នកនិពន្ធនៃបទគម្ពីរនេះ ក៏បានរៀបរាប់បន្តទៀតថា បុត្រដែលនឹងយាងមកប្រសូត្រនេះ ទ្រង់ជា "ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព"(អេសាយ ៩:៦)។

មីកា ៥:១ : បទគម្ពីរនេះ បានថ្លែងទំនាយថា ភូមិបេថ្លេហិម នឹងក្លាយជាទីកន្លែងកំណើតរបស់ ព្រះដែលនឹងយាងមកចាប់កំណើតនោះ គឺដូចមានសេចក្តីចែងថា :

*តែឯង ឱបេថ្លេហិម-អេប្រាតាអើយ ... នឹងមានម្នាក់កើតចេញពីឯងមកឲ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែល ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក។*

អេសាយ ៥៣ : ក្នុងបទគម្ពីរនេះ យើងអាចអានបទទំនាយដ៏ច្បាស់ មួយ

ចំនួន អំពីព្រះគ្រីស្ទដែលត្រូវយាងមកប្រសូត្រ។

*ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្តីឈឺចាប់ ទ្រង់ត្រូវគេមើលងាយ ដូចជាអ្នកណាដែលមនុស្សគេចមុខចេញ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ។*

*ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា តែទ្រង់ត្រូវរបួសដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់* (ខ.៣-៥)។

បទគម្ពីរទាំងនោះ មិនគ្រាន់តែបានចែងថា ព្រះគ្រីស្ទជាព្រះប៉ុណ្ណោះទេ តែថែមទាំងបានចែងថា ទ្រង់បានរងទុក្ខវេទនារហូតដល់សុគត ដើម្បីឲ្យយើងអាចទទួលសន្តិភាព និងការប្រោសឲ្យជាពីព្រះ។ ការសុគតរបស់ទ្រង់ នឹងបានផ្សះផ្សារទំនាក់ទំនងរវាងមនុស្ស និងព្រះ ដែលបានកាត់ផ្តាច់ដោយអំពើបាប(ដែលជាភាពអាត្មានិយមរបស់យើង)។ បទទំនាយ ក្នុងបទគម្ពីរអេសាយ ជំពូក៥៣ បានបន្តប្រាប់យើងថា ព្រះគ្រីស្ទនឹងសុគត ដោយសារអំពើទុច្ចរិតរបស់យើង ហើយនឹងទទួលរងទុក្ខវេទនា *ដោយស្ម័គ្រព្រះទ័យ* (ខ.៦-៧)។

ហេតុអ្វីបានជាព្រះគម្ពីរសញ្ញាចាស់ ចាំបាច់ត្រូវថ្លែងទំនាយ អំពីព្រះគ្រីស្ទដែលនឹងយាងមកប្រសូត្រ នៅសតវត្សរ៍ទី១?

## ព្រះគម្ពីរសញ្ញាថ្មី

ព្រះគម្ពីរសញ្ញាថ្មី ត្រូវបាននិពន្ធ ដោយមនុស្សដែលបានរស់នៅ ក្នុងសម័យដែលព្រះយេស៊ូវយាងមកជាលើកទី១។ ព្រះគម្ពីរសញ្ញាថ្មីមានពេញទៅដោយបទគម្ពីរដែលជាសេចក្តីសំអាង អំពីការដែលព្រះយេស៊ូវបានសម្រេចបទទំនាយ ឬព្រះបន្ទូលសន្យា ក្នុងព្រះគម្ពីរសញ្ញាចាស់។ ព្រះគម្ពីរសញ្ញាចាស់ គឺប្រៀបបាននឹង

"ប្រវត្តិរូប" របស់ព្រះយេស៊ូវ ហើយចំណែកឯព្រះគម្ពីរសញ្ញាថ្មីវិញ គឺបានបង្ហាញថា ព្រះយេស៊ូវពិតជាមានលក្ខណៈសម្បត្តិដែលត្រូវនឹងប្រវត្តិរូបនោះឥតខ្ចោះ។ ឧទាហរណ៍ :

ម៉ាថាយ ១:២២-២៣ : *ការទាំងនោះកើតមក ដើម្បីឲ្យបានសំរេចសេចក្តីដែលព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល ដោយសារហោរាថា «មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយព្រះនាមបុត្រនោះត្រូវហៅថា អេម៉ាញូអែល» ដែលប្រែថា ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ។*

កណ្ឌគម្ពីរនេះ ក៏បានរៀបរាប់បន្តទៀតថា ព្រះយេស៊ូវបានប្រសូត្រនៅបេថ្លេហិម(ម៉ាថាយ ២:១-៦) គឺសម្រេចតាមបទទំនាយរបស់ព្រះគម្ពីរមីកា។

ម្យ៉ាងទៀត បទទំនាយរបស់ បទគម្ពីរអេសាយ ៥៣:៦-៧ ក៏បានសម្រេចដោយព្រះយេស៊ូវ ពេលគេចាប់ទ្រង់ ហើយកាត់ទោសប្រហារជីវិតទ្រង់។ ទ្រង់មិនបានប្រឆាំងនឹងការចាប់ខ្លួននោះទេ តែបានស្ម័គ្រព្រះទ័យយាងទៅឈើឆ្កាងដើម្បីយើងរាល់គ្នា។

មានបទទំនាយជាច្រើនទៀត ដែលព្រះយេស៊ូវបានសម្រេច ដែលកូនសៀវភៅនេះមិនអាចបង្ហាញអស់។ លោកអ្នកអាចសាកសួរមិត្តភក្តិដែលជាគ្រីស្ទបរិស័ទ ឬអ្នកដឹកនាំពួកជំនុំរបស់អ្នក ឲ្យចែកចាយ អំពីការដែលព្រះយេស៊ូវបានបង្ហាញអត្តសញ្ញាណរបស់ទ្រង់ តាមរបៀបផ្សេងទៀត។ យើងក៏អាចស្វែងយល់បន្ថែម អំពីព្រះយេស៊ូវ ដោយស្តាប់ពាក្យពេចន៍ របស់អ្នកដែលស្គាល់ទ្រង់ជិតដិតបំផុត។

## ពាក្យពេចន៍របស់អ្នកដើរតាមទ្រង់

លោកយ៉ូហាន ស្ថិតក្នុងចំណោមមនុស្សដែលដើរតាមព្រះយេស៊ូវដំបូងគេ។ គាត់បានកត់ត្រា អំពីជីវប្រវត្តិរបស់ព្រះយេស៊ូវ ក្នុងនាមជាសាក្សីដែលបានឃើញផ្ទាល់ភ្នែក។ នៅខាងដើម នៃព្រះគម្ពីរយ៉ូហាន ដែលគាត់បាននិពន្ធ គាត់បានពិពណ៌នាអំពីព្រះយេស៊ូវថា "យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រា

តែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត"(យ៉ូហាន ១:១៤)។ លោកយ៉ូហាន បានមានប្រសាសន៍ថា ព្រះយេស៊ូវជាព្រះ ដែល "យាងចុះមកពីព្រះវរបិតា" ដើម្បីឲ្យគេបាន "ឃើញ" ហើយទ្រង់បានយកកំណើតជាមនុស្ស។

មានពេលជាច្រើនដង ដែលសាវ័កយ៉ូហាន បានកត់ត្រាយ៉ាងច្បាស់ អំពីការដែលព្រះយេស៊ូវមានបន្ទូលអំពីអត្តសញ្ញាណរបស់ទ្រង់។ គឺដូចដែលមានចែងក្នុងបទគម្ពីរ យ៉ូហាន ៨:២៣,៥៨ ១៤:១-៧ និងបទគម្ពីរជាច្រើនទៀត ក្នុងកណ្ឌមួយនេះ។

មិនមែនមានតែសាវ័កយ៉ូហានទេ ដែលបាននិយាយថា ព្រះយេស៊ូវជាព្រះ។ សាវ័កប៉ុល ក៏ស្ថិតក្នុងចំណោមអ្នកដើរតាមព្រះយេស៊ូវ ក្នុងសម័យពួកជំនុំដំបូងផងដែរ ដែលកាលពីមុន គាត់ជាអ្នកស្អប់ និងបៀតបៀនគ្រីស្ទបរិស័ទ។ គាត់បានសរសេរសំបុត្រជាច្រើន ទៅកាន់គ្រីស្ទបរិស័ទ និងពួកជំនុំ នៅកន្លែងខុសៗគ្នា។ ក្នុងសំបុត្រនោះ គាត់តែងតែបញ្ជាក់ថា ព្រះយេស៊ូវជាព្រះ។

គឺដូចមានចែងក្នុងបទគម្ពីរ ភីលីព ២:៥-៧ ថា *ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង* ។

បទគម្ពីរនេះបានបញ្ជាក់ថា ព្រះយេស៊ូវជាព្រះមួយរយភាគរយ និងមនុស្សមួយរយភាគរយ។ ទ្រង់ជាព្រះតាំងពីអស់កល្បជានិច្ច ដល់អស់កល្បជានិច្ច។ តែទ្រង់បានលះបង់សិរីល្អរបស់ទ្រង់ ដើម្បីយកកំណើតជា "មនុស្ស" ជាអ្នកបម្រើដែលបន្ទាបខ្លួន និងស្តាប់បង្គាប់ព្រះវរបិតារហូតដល់សុគត។ ព្រះយេស៊ូវជាព្រះហើយនៅតែជាព្រះ ទោះទ្រង់បានយកកំណើតជាមនុស្សហើយក៏ដោយ។ តើសាវ័កយ៉ូហាន និងសាវ័កប៉ុល(ក៏ដូចជា មនុស្សជាច្រើនទៀត) មានការយល់ខុសអំពីព្រះយេស៊ូវឬ? តើពួកគេកំពុងនិយាយកុហក់អំពីទ្រង់ ដោយចេតនាឬ? តើពួកគេមានគំនិតស្រមើស្រមៃ ដោយយល់ថា ព្រះយេស៊ូវជាព្រះឬ? គឺមិនដូច្នោះទេ។ ព្រះយេស៊ូវក៏បានអះអាងដោយព្រះអង្គទ្រង់ផ្ទាល់ថា ទ្រង់ជាព្រះ។

# ព្រះបន្ទូលរបស់ព្រះយេស៊ូវ

ពេលយើងស្វែងយល់អំពីអត្តសញ្ញាណរបស់ព្រះយេស៊ូវ ការសំខាន់បំផុតដែលយើងត្រូវធ្វើ គឺត្រូវស្តាប់ព្រះយេស៊ូវមានបន្ទូលអ្វីខ្លះ អំពីព្រះអង្គទ្រង់។ ទ្រង់បានធ្វើការអះអាងដ៏គួរឲ្យភ្ញាក់ផ្អើល អំពីព្រះអង្គទ្រង់ថា

*កូនមនុស្សត្រូវបញ្ជូនទៅក្នុងកណ្ដាប់ដៃនៃមនុស្សលោក គេនឹងសំឡាប់លោក រួចដល់៣ថ្ងៃក្រោយដែលគេសំឡាប់ នោះលោកនឹងរស់ឡើងវិញ។-* ម៉ាកុស ៩:៣១

ព្រះយេស៊ូវបានមានបន្ទូលយ៉ាងច្បាស់ អំពីអត្តសញ្ញាណ និងបេសកកម្មរបស់ទ្រង់ គឺទ្រង់បានមក ដើម្បីសុគត ដើម្បីយើងរាល់គ្នា ហើយបីថ្ងៃក្រោយមកទ្រង់មានព្រះជន្មរស់ឡើងវិញ។ ពេលទ្រង់មានបន្ទូលដូចនេះ តើទ្រង់បានទទួលការឆ្លើយតបយ៉ាងដូចម្ដេចខ្លះ?

ជនជាតិយ៉ូដា មិនយល់ ព្រះបន្ទូលព្រះយេស៊ូវទេ។ តាមពិត ព្រះបន្ទូលទ្រង់បានធ្វើឲ្យពួកគេខឹងយ៉ាងខ្លាំង ព្រោះទ្រង់បានអះអាងថា ទ្រង់ជាព្រះ បានជាពួកគេព្យាយាមធ្វើគុតទ្រង់ឲ្យទាល់តែបាន! ក្នុងការសន្ទនាដ៏តឹងតែង រវាងព្រះយេស៊ូវ និងអ្នកដឹកនាំនៃសាសន៍យូដាមួយក្រុម ទ្រង់បានមានបន្ទូលថា "ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មុនដែលលោកអ័ប្រាហាំកើតមក នោះមានខ្ញុំហើយ" (យ៉ូហាន ៨:៥៨)។ ក្នុងព្រះគម្ពីរដើមជាភាសាក្រិក ពាក្យថា "មានខ្ញុំហើយ" គឺស្មើនឹងការនិយាយថា "អញជាព្រះដ៏ជាព្រះ"ដែលជាព្រះនាមមួយទៀតរបស់ព្រះ ដែលទ្រង់បានប្រើ ក្នុងគ្រាសញ្ញាចាស់(និក្ខមនំ ៣:១៤)។ ត្រង់ចំណុចនេះ អ្នកដឹកនាំសាសនារបស់សាសន៍យូដា បានយល់យ៉ាងច្បាស់ថា ព្រះយេស៊ូវកំពុងហៅព្រះអង្គទ្រង់ថា ព្រះ។ ហើយពួកគេក៏បានបដិសេធន៍មិនជឿទ្រង់។ ផ្ទុយទៅវិញ ពួកគេចង់សម្លាប់ទ្រង់ ដោយចោលនឹងថ្ម ដោយសារទ្រង់បានអះអាងថា ខ្លួនជាព្រះ។

មានពេលមួយទៀត ពេលព្រះយេស៊ូវកំពុងបង្រៀន ដល់ពួកបណ្ដាលជន

ទ្រង់បានសួរគេថា "តើមនុស្សទាំងឡាយ គេថាកូនមនុស្សជាអ្នកណា?"(ម៉ាថាយ ១៦:១៣)។ បន្ទាប់ពី ទ្រង់បានជ្រាបថា ពួកបណ្ដាជនគិតថា ទ្រង់ជានរណាហើយ (ជាមនុស្សល្អ គ្រូបង្រៀន ។ល។) ទ្រង់ក៏បានសួរសំណួរដដែលនេះ ដល់ពួកសិស្សដែលជិតដិតនឹងទ្រង់ជាងគេថា "ចុះឯអ្នករាល់គ្នាវិញ តើថាខ្ញុំជាអ្នកណា"(ខ.១៥)។ ពួកសិស្សទ្រង់ ដែលជិតដិតនឹងទ្រង់ជាងគេ បានគិតខុសពីពួកបណ្ដាជន។ ជាក់ស្ដែង លោកស៊ីម៉ូន ពេត្រុសបានទូលទ្រង់ថា "ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់"(ខ.១៦)។ ពេលនោះ ព្រះយេស៊ូវមិនបានបដិសេធន៍នឹងចម្លើយនេះទេ ផ្ទុយទៅវិញ ទ្រង់បានមានបន្ទូលស្របថា "អ្នកស៊ីម៉ូន កូនយ៉ូណាសអើយ អ្នកមានពរ ដ្បិតមិនមែនជាសាច់ឈាម ដែលបានសំដែងឲ្យអ្នកស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំដែលគង់នៅស្ថានសួគ៌វិញ"(ខ.១៧)។ ព្រះយេស៊ូវបានអះអាងថា ទ្រង់ជាព្រះ ហើយសព្វព្រះទ័យឲ្យសិស្សទ្រង់ជឿ ហើយពឹងផ្អែកលើសេចក្ដីពិតនេះផងដែរ។

គួរឲ្យកត់សំគាល់ផងដែរថា ការសង្ស័យ ក៏ជាការឆ្លើយតប ដែលកើតមានជាធម្មតា។ បន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មឡើងវិញ បានជាងមួយសប្ដាហ៍ លោកថូម៉ាស (ដែលជាសិស្សម្នាក់ទៀត របស់ព្រះយេស៊ូវ) មិនទាន់បានឃើញទ្រង់ទេ។ គាត់មិនព្រមជឿថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញឡើយ។ បានជាគាត់និយាយថា "បើខ្ញុំមិនឃើញស្នាមដែកគោល នៅព្រះហស្ដទ្រង់ ទាំងលូកម្រាមទៅក្នុងស្នាមដែកគោលនោះ ហើយលូកដៃខ្ញុំទៅក្នុងចំហៀងទ្រង់ នោះខ្ញុំមិនព្រមជឿទេ"(យ៉ូហាន ២០:២៥)។

*ដល់៨ថ្ងៃក្រោយមក ពួកសិស្សទ្រង់នៅក្នុងផ្ទះម្តងទៀត ហើយថូម៉ាសក៏នៅជាមួយដែរ នោះព្រះយេស៊ូវទ្រង់យាងមក ឈរកណ្តាលពួកគេ ទាំងទ្វារនៅបិទ ហើយមានព្រះបន្ទូលថា សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត។ រួចទ្រង់មានព្រះបន្ទូលទៅថូម៉ាសថា ចូរលូកម្រាមដៃអ្នកមក ស្ទាបមើលដៃខ្ញុំឯណេះ ហើយលូកដៃមកក្នុងចំហៀងខ្ញុំផង កុំឲ្យមានចិត្តមិនជឿឡើយ ត្រូវឲ្យជឿចុះ។*-យ៉ូហាន ២០:២៦-២៧

ព្រះយេស៊ូវជ្រាបថា លោកថូម៉ាសមានការសង្ស័យ តែទ្រង់មិនបានបដិសេធគាត់ទេ ផ្ទុយទៅវិញ ទ្រង់បានបង្ហាញភស្តុតាង ឲ្យលោកថូម៉ាសជឿថា ទ្រង់ពិតជាបានមានព្រះជន្មរស់ឡើងវិញមែន។ លោកថូម៉ាសក៏បានឆ្លើយតប ដោយក្តីញាប់ញ័រថា "ឱព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ"(ខ.២៨)។ ត្រង់ចំណុចនេះ លោកថូម៉ាសបានទទួលស្គាល់ថា ព្រះយេស៊ូវពិតជាមានព្រះជន្មរស់ឡើងវិញ ហើយបានសេចក្តីថា ទ្រង់ពិតជាព្រះប្រាកដមែន។

ព្រះយេស៊ូវក៏ជ្រាបអំពីការសង្ស័យរបស់យើងផងដែរ ហើយទ្រង់សព្វព្រះទ័យនិងឲ្យតម្លៃទៅលើភាពស្មោះត្រង់របស់យើង។ ទ្រង់សព្វព្រះទ័យឲ្យយើងនិយាយទៅកាន់ទ្រង់ ហើយអានព្រះគម្ពីរដើម្បីស្វែងយល់អំពីទ្រង់ ដើម្បីឲ្យយើងដឹងច្បាស់ថា ទ្រង់ជានរណា។

## តើអ្នកថា ទ្រង់ជានរណា?

លោកស៊ី អេស លូអ៊ីស(C. S. Lewis) ដែលជាអ្នកនិពន្ធគ្រីស្ទបរិស័ទ បានបកស្រាយថា យើងមានជម្រើសតែបីប៉ុណ្ណោះ នៅក្នុងការស្គាល់អត្តសញ្ញាណរបស់ព្រះយេស៊ូវ។ គឺដូចដែលគាត់បានមានប្រសាសន៍ថា:

*មនុស្សណា ដែលតាំងខ្លួនជាព្រះ ដូចដែលព្រះយេស៊ូវបានអះអាងថា ទ្រង់ជាព្រះ អ្នកនោះមិនមែនជាគ្រូបង្រៀនសីលធម៌ដ៏អស្ចារ្យនោះទេ។ អ្នកនោះជាមនុស្សឆ្កួត គឺមិនខុសពីអ្នកដែលថាខ្លួនឯងជាពងទាស្ងោរឡើយ ពុំនោះទេគាត់គឺជាអារក្សនៃស្ថាននរកហើយ។ អ្នកត្រូវធ្វើការសម្រេចចិត្ត។ បើព្រះយេស៊ូវ មិនមែនជាព្រះរាជបុត្រានៃព្រះ ដូចការអះអាងរបស់ទ្រង់ទេ នោះទ្រង់ជាមនុស្សឆ្កួត ឬអាក្រក់លើសពីនេះទៅទៀត។ បើទ្រង់និយាយកុហក់ នោះអ្នកអាចថា ទ្រង់ជាមនុស្សឡប់សតិ ឬអាចស្តោះទឹកមាត់ដាក់ទ្រង់ ហើយសម្លាប់ទ្រង់ ដោយថាទ្រង់ជាបិសាច តែបើទ្រង់មិននិយាយកុហក់ទេ នោះអ្នកអាចលុតជង្គង់ក្រាប នៅទាបព្រះបាទទ្រង់ ហើយហៅទ្រង់ថា ព្រះអម្ចាស់ និងព្រះ។ តែយើងមិនត្រូវមានគំនិតឥតន័យ ដោយគិតថា ទ្រង់ជាគ្រូបង្រៀន*

*ដ៏អស្ចារ្យម្នាក់នោះឡើយ។ ទ្រង់មិនបានបើកឲ្យយើងគិតយ៉ាងដូចនេះទេ។*

ត្រង់ចំណុចនេះ លោកលូអ៊ីសកំពុងនិយាយថា បើព្រះយេស៊ូវមិនមែនជាព្រះទេ នោះទ្រង់ជាមនុស្សឆ្កួត ឬកំពុងនិយាយកុហក់។ តែអ្នកដែលបានស្គាល់ព្រះយេស៊ូវច្បាស់ បានទទួលស្គាល់ថា ទ្រង់មិនមែនជាមនុស្សឡប់ ឬមនុស្សកុហក់ទេ។ ពួកគេដឹងថា ទ្រង់ជាព្រះ ពួកគេថែមទាំងបានកត់ត្រាអំពីទ្រង់ ក្នុងនាមជាសាក្សីដែលបានឃើញការពិត ដើម្បីឲ្យយើងស្គាល់សេចក្តីពិត។ មនុស្សជាច្រើនសុខចិត្តស្លាប់ជាជាងបដិសេធថា ទ្រង់មិនមែនជាព្រះ។ គេមិនអាចប្រើគំនិតដែលឆ្កួតឡប់ ឬគំនិតអាក្រក់ ដើម្បីបកស្រាយពន្យល់ អំពីដំណើរជីវិត ការសុគត និងការមានព្រះជន្មឡើងវិញរបស់ព្រះយេស៊ូវ បូករួមនឹងសេចក្តីស្រឡាញ់ និងប្រាជ្ញាទ្រង់បានឡើយ។

ព្រះបន្ទូល និងសកម្មភាពរបស់ព្រះយេស៊ូវ បានបង្ហាញថា ទ្រង់ជាព្រះ។ ព្រះយេស៊ូវបានសម្រេចបទទំនាយ អំពីអង្គបុគ្គល ដែលជាព្រះយាងចុះមកផែនដី។ ទ្រង់បានបង្ហាញនូវចារិកលក្ខណៈ និងសេចក្តីស្រឡាញ់របស់ព្រះដ៏អស់កល្បជានិច្ច។ ទ្រង់បានធ្វើនូវការជាច្រើន ដែលមានតែព្រះទេដែលអាចធ្វើបាន។

មនុស្សវិកលចរិកអាចអះអាងថាយ៉ាងម៉េចក៏បាន តែមិនអាចផ្តល់ឲ្យនូវភស្តុតាង។ មនុស្សកុហក់អាចបោកឲ្យគេជឿយ៉ាងជំនាញ តែមិនអាចបង្ហាញថា អ្វីដែលខ្លួននិយាយជាការពិត ហើយទីបំផុតគេក៏ដឹង។ ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវបានយាងមកប្រសូត្រ នៅចំកន្លែងដែលមនុស្ស ដែលមានលក្ខណៈជាព្រះបានប្រសូត្រ បានរស់នៅជាមនុស្សដែលមានលក្ខណៈជាព្រះ បានសុគតជាមនុស្សដែលមានលក្ខណៈជាព្រះ ហើយបានមានព្រះជន្មរស់ឡើងវិញ ដែលមានតែព្រះទេ ដែលអាចធ្វើបាន។

> *ព្រះបន្ទូល និងសកម្មភាពរបស់ព្រះយេស៊ូវ បានបង្ហាញថា* ***ទ្រង់ជាព្រះ។***

តើអ្នកគិតថា ព្រះយេស៊ូវជានរណា? អនាគត និងជីវិតអស់កល្បរបស់អ្នក គឺពឹងផ្អែកទៅលើការសម្រេចចិត្តរបស់អ្នកថា ទ្រង់ជានរណា។ យើងមិនត្រូវ

ធ្វើព្រងើយចំពោះព្រះយេស៊ូវឡើយ តែត្រូវធ្វើការសម្រេចចិត្ត។ សូមជជែកជាមួយនរណាម្នាក់ ក្នុងពួកជំនុំរបស់អ្នក ឬជាមួយគ្រីស្ទបរិស័ទដទៃទៀត ដែលអ្នកស្គាល់។ សូមសួរពួកគេថា តើពួកគេយល់ថា ព្រះយេស៊ូវជានរណា ហើយសួរថា ហេតុអ្វីពួកគេ ឆ្លើយដូចនោះ?

ប្រែសម្រួលជាភាសាខ្មែរ ដោយ : លោក ឯក សត្យា

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤

ដោយការអនុញ្ញាត និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2015 ODB Ministries ( website: www.odb.org )

ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@rbc.org, Tell: 087 233 907, website: http://khmer-odb.org, FB page : https://www.facebook.com/RBCCambodia )